**Entrapment (Andrew L-T CHOO, Abuse of Process and Judicial Stays of Criminal Proceedings, 2nd, 2011, pp. 133-154)**

**ពាក្យគន្លឹះ÷** ការបំពាននីតិវិធី កម្រិតនៃភស្តុតាង ...

**១.** វិធីសាស្រ្តស៊ើបអង្កេត មានច្រើនប្រភេទ។ ក្នុងសម័យបូរាណ គឺការសាកសួរ..ក៏ប៉ុន្តែ ក្នុងសម័យនេះ ដោយសារបទល្មើសខ្លះ ត្រូវបានប្រព្រឹត្តក្នុងលក្ខណៈស្មុគ្រស្មាញ (organized crime) វិធីសាស្រ្តស៊ើបអង្កេតថ្មីៗ ត្រូវបានប្រើប្រាស់ ដូចជា Entrapment (E) ជាវិធីសាស្រ្តមួយនៃការស៊ើបអង្កេតចាប់ជនសង្ស័យ ដែលអាចជាការបំពានចូលក្នុងប្រភេទនៃការបំពាននីតិវិធី (abuse of process) ដែលអាចនាំឲ្យមានការផ្អាកនីតិវិធីជាអចិន្ត្រៃយ៍។

**២.** E កើតមាននៅពេលភ្នាក់ងាររបស់រដ្ឋ ជាទូទៅមន្ត្រីអនុវត្តច្បាប់ ឬអ្នកផ្តល់ព័ត៌មាន (controller informer) **ជម្រុញបុគ្គលណាមួយ ឲ្យប្រព្រឹត្តបទល្មើស ដើម្បីជននោះត្រូវបានចោទប្រកាន់។** ពីពេលមុនប្រទេសអង់គ្លេស មិនបានហាមឃាត់ និងមិនចាត់ថា E គឺជាការការខ្លួនទេ ក៏ប៉ុន្តែអាចជាស្ថានសម្រាល។ នេះខុសពីសហរដ្ឋអាមេរិក ដែលចាត់ថា E ជាការបំពាននីតិវិធី ដែលនាំជនជាប់ចោទ អាចលើកយកជាការដោះសារ ហើយប្រសិនបើរដ្ឋអាជ្ញាមិនបានបង្ហាញថា ជនល្មើសមិនត្រូវបាន entrapped ទេ នឹងនាំឲ្យមានការរួចផុតបទចោទប្រកាន់។ ការសម្រេចមិនបដិសេធ E អាចជាការយោគយល់ដល់ទង្វើខុសឆ្គងរបស់នគរបាល នាំឲ្យសាធារណជនបាត់ទំនុកចិត្តលើប្រព័ន្ធយុត្តិធម៌។ ក្រោយពីទទួលឥទ្ធិពលពីយុត្តិសាស្រ្តរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ...*ខណៈបទល្មើសមានអង្គការចាត់តាំង ទាមទារថា វិធានការសមស្របត្រូវបានប្រកាន់យក សិទ្ធិទទួលបានការចាត់ចែងយុត្តិធម៌ឲ្យសមស្រប បានដើរតួនាទីយ៉ាងសំខាន់....*[1] តុលាការអង់គ្លេស បានប្តូរជំហរពាក់ព័ន្ធនឹង E។ មានច្បាប់និងវិធានមួយចំនួន ត្រូវបានអនុម័ត ដូចជា

[1] The use of undercover agents must be restricted and safeguards put in place even in cases concerning the fight against drug-trafficking. While the rise in organized crime undoubtedly requires that appropriate measures to be taken, the right to a fair administration of justice nevertheless holds such a prominent place...that it cannot be sacrificed for the sake of expedience. The general requirements of fairness embodied in Article 6 apply to proceedings concerning all types of criminal offence, from the most straightforward to the most complex. The public interest can not justify the use of evidence obtained as a result of police incitement.

Regulation of Investigatory Powers Act 2000 និង Code of Practice ហើយតុលាការបានអនុវត្តជាក់ស្តែង។

៣. តាមយុត្តិសាស្ត្ររបស់តុលាការអង់គ្លេស E មិនត្រូវបានហាមឃាត់ទេ ក៏ប៉ុន្តែត្រូវតែបានធ្វើឡើងដោយត្រឹមត្រូវតាមនីតិវិធីច្បាប់ ដើម្បីរួចផុតពីផលវិបាកនៃការផ្អាកនីតិវិធី។ មានកត្តាជាច្រើន ដែលនឹងត្រូវបានពិចារណា÷ **ក.** ថាតើ E វានឹងធ្វើឲ្យការវិនិច្ឆ័យសេចក្តីមិនយុត្តិធម៌។ **ខ.** ទោះបីជាវាអាចមានយុត្តិធម៌ក្តី តុលាការនៅតែនឹងមិនធ្វើសវនាការ ប្រសិនបើធ្វើដូចនេះ វានឹងប៉ះដល់កិត្យានុភាពនៃតុលាការ។ **គ.** ការផ្អាកនីតិវិធី អាចប៉ះពាល់ដល់ការងារស៊ើបអង្កេតរបស់នគរបាល ឬផលប្រយោជន៍សាធារណៈ ដែលសាធារណជន ចង់ឃើញជនល្មើស ជាពិសេស ក្នុងបទល្មើសធ្ងន់ធ្ងរ ត្រូវបានកាត់ទោស ដូចនេះ ការសម្រេចផ្អាកឬមិនផ្អាក ចៅក្រមត្រូវពិនិត្យមើលនីតិវិធីទាំងមូល រួមទាំងការថ្លឹងថ្លែងរវាងផលប្រយោជន៍ទាំងសង្ខាង (balance of interest)។ ក្នុងន័យនេះ ចៅក្រមនឹងពិនិត្យមើលថាតើប្រភេទបទល្មើសអ្វី (ពិបាកក្នុងការស៊ើបអង្កេត?) ការប្រើប្រាស់វិធីនេះ ចាំបាច់ដើម្បីសន្តិសុខជាតិ...វិធីសាស្ត្រនេះសមាមាត្រ (proportionate) នគរបាលធ្វើនោះដោយសុទ្ធចិត្ត (good faith) ជាការស៊ើបអង្កេតពិតប្រាកដ (bona fide inquiry) តើការធ្វើដោយប៉ូលីស មានការអនុញ្ញាតដែរឬទេ? កម្រិតនៃការចូលរួមរបស់នគរបាលក្នុង E មានកម្រិតណា?។

៤. សម្រាប់កម្រិតនៃភស្តុតាងវិញ តុលាការប្រើ “but for test” ដើម្បីបង្ហាញថា អំពីចំណងហេតុនឹងផល (causation) ថាតើប្រសិនបើគ្មានការញុះញង់ដោយប៉ូលីសសម្ងាត់ទេ បទល្មើសនឹងមិនត្រូវបានប្រព្រឹត្តិឡើង។ ពាក់ព័ន្ធនឹងចំណុចនេះ ទ្រឹស្តីស្តីពី unexceptional opportunity to commit the offense ត្រូវបានអភិវឌ្ឍ ក្នុងន័យថា ជនល្មើសមិនមានឱកាសក្នុងការប្រព្រឹត្ត ដោយពិចារណាលើ ការល្មើសកន្លងមកស្រដៀងគ្នាក្នុងពេលអតីតកាល (reasonable suspicion)។ នេះជាការឆ្លើយតបទៅនឹង អង្គហេតុដែលថា ក្នុងករណីខ្លះអ្នកប្រព្រឹត្ត មិនមានប្រវត្តិប្រព្រឹត្តល្មើស ឬអាជ្ញាធរមានការសង្ស័យថាបានប្រព្រឹត្ត។ ក៏ប៉ុន្តែគាត់បានក្លាយជាអ្នកប្រព្រឹត្តបទល្មើស ដោយសារតែការញុះញង់របស់នគរបាលសម្ងាត់ ដែលធ្វើហួសពីតួនាទីជាអ្នកស៊ើបអង្កេត។

**៥.** E បានប៉ះពាល់ជាខ្លាំងដល់សិទ្ធិទទួលបានការកាត់សេចក្តីដោយយុត្តិធម៌។ ទន្ទឹមនឹងនេះ នីតិវិធីដើម្បីសុំផ្អាកផ្នែកលើ E ដែលជាការបំពាននីតិវិធី ត្រូវបានអាក់ខាន ដោយរបាំងអភ័យឯកសិទ្ធិប្រយោជន៍សាធារណៈ (public interest immunity) ដែលរារាំងមិនឲ្យមានការបញ្ចេញព័ត៌មាន។ ជាចុងក្រោយ មានសំណួរសួរថា តើ E ដោយបុគ្គលឯកជន (អ្នកកាសែតចូលបន្ទប់វេជ្ជបណ្ឌិត ធ្វើជាឈឺ ដើម្បីទទួលបានលិខិតបញ្ជាក់ជំងឺ នាំឲ្យមានការចោទប្រកាន់លើវេជ្ជបណ្ឌិត) ឬធ្វើឡើងក្នុងសមត្ថកិច្ចជាជនស៊ីវិល ជាការបំពាននាំឲ្យមានការផ្អាកនីតិវិធីដែរឬទេ?។ ចម្លើយគឺវិជ្ជមាន ពីព្រោះប្រសិនបើតុលាការនៅតែបន្តនីតិវិធី វានឹងប៉ះដល់កិត្យានុភាពនៃប្រព័ន្ធយុត្តិធម៌។ ម្យ៉ាងទៀតអាជ្ញាធរ អាចលើកថា គាត់ធ្វើក្រៅសមត្ថកិច្ចជាដើម។